សេចក្តីសម្រេចចិត្ត
នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ២៥៧០
ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦ បានដំណើរការរយៈពេលមួយព្រឹកពេញ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល មានចំនួនសរុប១៨០រូប(ស្ត្រី៥៥រូប)។

កិច្ចប្រជុំបានវាយតម្លៃខ្ពស់ អបអរសាទរ និងសម្តែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅជូនចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអង្គការជាតិ-អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្តុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានរួមសហការ និងប្រឹងប្រែងយ៉ាងសកម្មក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។ តាមរយៈការរួមចំណែកដ៏មានតម្លៃនេះ ធ្វើឱ្យកម្ពុជាទទួលបានការប្រកាសទទួលស្គាល់ពីអង្គការសហប្រជាជាតិជាប្រទេសទីមួយក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលសម្រេចបានគោលដៅ៩៥-៩៥-៩៥ មុនកាលកំណត់របស់អង្គការសហប្រជាជាតិ(UNAIDS)។

ផ្អែកលើលទ្ធផលនៃការពិភាក្សា និងការផ្លាស់ប្តូរយោបល់យ៉ាងទូលំទូលាយ កិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦ បានសម្រេចដាក់ចេញនូវទិសដៅការងារដូចតទៅ៖

១- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តត្រូវបន្តជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកានានា ដើម្បីបញ្ជ្រាបការយល់ដឹងអំពីហានិភ័យមេរោគអេដស៍ ការមាក់ងាយ រើសអើង ដោយទាក់ទាញនិងលើកទឹកចិត្តដល់ប្រជាជនទូទៅ ជាពិសេសប្រជាជនគន្លឹះមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ថែទាំព្យាបាលឱ្យបានទាន់ពេលវេលា ទូលំទូលាយ និងតាមលទ្ធភាព។

២- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត បន្តជំរុញការផ្សព្វផ្សាយ និងអនុវត្តនូវសារាចររបស់រាជរដ្ឋាភិបាលលេខ ២០ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០ភាគរយ ដើម្បីបង្ការមេរោគអេដស៍និងជំងឺអេដស៍។

៣- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ បន្តណែនាំ និងជំរុញរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ អនុវត្តសារាចរអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ

លេខ០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។

៤- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ បន្តណែនាំ និងជួយសម្របសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញជាដៃគូ មន្ទីរពាក់ព័ន្ធ(ផែនការ ទេសចរណ៍ សុខាភិបាល) និងបេឡាជាតិសន្តិសុខសង្គម ជំរុញប្រជាជនគន្លឹះបម្រើការក្នុងសេវាកម្មាន្តទេសចរណ៍ មានជាអាទិ៍ បុរសរួមភេទជាមួយបុរស(MSM) អ្នកបំប្លែងភេទ(TG) ស្ត្រីបម្រើក្នុងសេវាកម្មាន្ត (EW) មកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគ និងប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍នានា ព្រមទាំងពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.) ដល់ប្រជាជនគន្លឹះ ឱ្យបានយ៉ាងឆាប់រហ័ស និងបានទូលំទូលាយ។

៥- ក្រសួងសុខាភិបាលបន្តពង្រីកសេវាធ្វើតេស្តរកមេរោគអេដស៍ សេវាបង្ការមុនពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PrEP) សេវាបង្ការក្រោយពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PEP) និងលើកទឹកចិត្តការប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវ និងជាប់លាប់ជាប្រចាំដល់ក្រុមគោលដៅ។

៦- ក្រសួងសុខាភិបាលបន្តពង្រឹង ពង្រីកសេវាថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍ឱ្យមានគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ ដោយគ្មានការរើសអើង។

៧- ក្រសួងសុខាភិបាល បន្តខិតខំកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យថយចុះបន្ថែមទៀត ដើម្បីសម្រេចបានគោលដៅលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (<៥%)។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦

ប្រធានអង្គប្រជុំ
ទេសរដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង ងួលី